# ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ ជួបអគ្គលេខាធិការអង្គការ WBI នៃប្រទេស បែលហ្ស៊ិក



នៅរសៀលថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ២០១៤ ឯកឧត្តម **ចម ប្រសិទ្ធ** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានទទួលជួបប្រតិភូអង្គការ **WBI** (Wallonie- Bruxelles Internatioanales) ដឹកនាំដោយឯកឧត្តម **Philippe Suinen** អគ្គលេខាធិការអង្គការ WBI នៃប្រទេស បែលហ្ស៊ិក ដើម្បីពិភាក្សាការងារ នៅទីស្តីការក្រសួង ។






ឯកឧត្តម **Philippe Suinen** អគ្គលេខាធិការអង្គការ **WBI** បានជម្រាបជូនថាៈ អង្គការរបស់លោក បានបង្កើតការិយាល័យរបស់ខ្លួន នៅរាជធានីភ្នំពេញ ដើម្បីសម្រួលកិច្ចការនាំចេញ-នាំចូល រវាងកម្ពុជា និងសហគមន៍អឺរ៉ុប ដែលកំពុងមានទំនាក់ទំនងនិងកិច្ចសហប្រតិបត្តិការដ៏ប្រសើរ ជាពិសេសការដោះដូរពាណិជ្ជកម្ម និងការវិនិយោគ ។ ជាមួយគ្នានេះ អង្គការ WBI ក៏បានសហការជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងការរៀបចំគម្រោងកម្មវិធីបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ក្នុងវិស័យរោងចក្រនៅកម្ពុជាផងដែរ ។ លោក អគ្គលេខាធិការអង្គការ WBI បានបង្ហាញនូវការមើលឃើញពីសារៈសំខាន់ នៃសហគ្រាសខ្នាតតូច និងមធ្យម និងវិស័យឧស្សាហកម្ម នៅកម្ពុជា ដែលកំពុងដើរតួយ៉ាងសំខាន់ ក្នុងចរន្តសេដ្ឋកិច្ចជាតិ និងបានបង្ហាញនូវការផ្តល់ការគាំទ្រលើវិស័យមួយចំនួនទៀត ។ ជាចំណុចចុងក្រោយ ឯកឧត្តម **Philippe Suinen** បានស្នើអញ្ជើញភាគីកម្ពុជា ដើម្បីទៅចូលរួមវេទិការប្រទេសនិយាយភាសារបារាំង ដែលនឹងប្រារព្ធធ្វើនាខែកក្កដា ឆ្នាំ២០១៥ ខាងមុខ ។

ឯកឧត្តម ទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** បានសម្តែងការស្វាគមន៍ និងបានចាត់ទុកអង្គការ WBI ដែលបានបង្កើតការិយាល័យរបស់ខ្លួន នៅកម្ពុជា គឺស្របពេលវេលា ដែលកម្ពុជាកំពុងជម្រុញល្បឿននៃសមាហរណកម្មសេដ្ឋកិច្ចរបស់ខ្លួន នៅក្នុងតំបន់ និងពិភពលោក ។ ក្នុងនោះ ទីផ្សារសហគមន៍អឺរ៉ុប ជាទីផ្សារដ៏សំខាន់មួយរបស់កម្ពុជា ។ ទាក់ទងនិងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ឯកឧត្តម ទេសរដ្ឋមន្ត្រី បានសាទរ និងគាំទ្រ ដោយបានបញ្ជាក់ថាៈ យុវជនកម្ពុជា ដែលដល់វ័យចូលបម្រើការងារ គឺមានចំនួន២៥ ម៉ឺននាក់ ក្នុងមួយឆ្នាំ ។ ដូច្នេះ ឯកឧត្តម បានស្នើឱ្យ អង្គការ WBI និង ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ កំណត់ជំនាញជាអាទិភាពដែលត្រូវបណ្តុះបណ្តាលឱ្យស្របនិងទីផ្សារការងារនៅកម្ពុជា ។ ឯកឧត្តម ទេសរដ្ឋមន្ត្រី បានផ្តល់ជាទស្សនៈថាៈការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ក្នុងវិស័យឧស្សាហកម្មកាត់ដេរសំលៀកបំពាក់ និងស្បែកជើងជាកត្តាសំខាន់មួយ ។ ក៏ប៉ុន្តែ កម្ពុជានៅត្រូវការជំនាញបន្ថែម និងមានលក្ខណៈខ្ពស់មួយកំរិតទៀត ក្នុងឧស្សាហកម្មថ្មីៗ ដូចជាឧស្សាហកម្មផ្នែកអេឡិចត្រូនិក-ឧស្សាហកម្មកែច្នៃ និងវិស្វកម្ម ជាដើម ។ ទាក់ទង និងគម្រោងគាំទ្រដល់សហគ្រាសនៅកម្ពុជា លើវិស័យមួយចំនួន ឯកឧត្តម ទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** បានចាត់ទុកជាវិស័យ

ដ៏សំខាន់  ជាពិសេស ដូចជាៈវិស័យ កសិ-ចំណីអហារ-មេកានិក និងវិស្វកម្ម-ភស្តុភា (Ligistic)- និងឧស្សាហកម្មស្អាត ។ ចំពោះការអញ្ជើញភាគីកម្ពុជាទៅចូលរួម ក្នុងវេទិការប្រទេសនិយាយភាសាបារាំង កម្ពុជានឹងពិនិត្យលទ្ធភាព ត្រៀមបញ្ជូនមន្ត្រីចូលរួម ហើយសង្ឃឹមថាៈប្រទេសប៊ែលហ្សិក នឹងសម្រួលឱ្យការចូលរួមរបស់មន្ត្រីកម្ពុជាសម្រេចបាន ជោគជ័យ ។